ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៦៧/១២-ស្តារ នីតធីង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ ម៉ារ សំបូរណា
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ រុន សារ៉ាយ

## ភាគីនៃវិវាទ

### ១-ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុនស្តារ នីតធីង & ហ្គាមេន ហ្វេកធើរី អិលធីឌី
អាសយដ្ឋាន ៖ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៩៨៦ ៩៣៣ ទូរសារ៖ គ្មាន
តំណាងភាគីនិយោជក ៖ អវត្តមាន

### ២-ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពប្រជាធិបតេយ្យសំណោងកម្មករ
- សហជីពប្រជាធិបតេយ្យសំណោងកម្មករនៃរោងចក្រកាត់ដេរ ស្តារ នីតធីង
អាសយដ្ឋាន ៖ ភូមិព្រែកសំរោង សង្កាត់ព្រែកសំរោង ក្រុងតាខ្មៅ ខេត្តកណ្តាល
លេខទូរស័ព្ទ ៖ ០១២ ៧០០ ២៩៩ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖

១- លោក តុំ គីមសឿន មន្ត្រីសម្របសម្រួលសហព័ន្ធសហជីពប្រជាធិបតេយ្យសំណោងកម្មករ
២- លោក ស៊ុយ ចន្ទា លេខាធិការសហព័ន្ធសហជីពប្រជាធិបតេយ្យសំណោងកម្មករ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◈ Website: www.arbitrationcouncil.org

៣- លោក សំ រិន ប្រធានសហជីពប្រជាធិបតេយ្យសំណាងកម្មករប្រចាំក្រុមហ៊ុន

## បញ្ហាក្តូចវិចារ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករទាមទារចំពោះកម្មករនិយោជិត មិនបានចូលធ្វើការថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ សុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលស្មើនឹង ៥០ % ទាំងអស់គ្នា រហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២។ ក្រុមហ៊ុនមិនឯកភាព។

២- ភាគីកម្មករសុំឱ្យក្រុមហ៊ុនបើកលុយអាណត្តិកិច្ចសន្យាការងារ នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២។ ក្រុមហ៊ុនមិនឯកភាព។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ២៨៣/១២ កប/កណ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ (វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានប្រជុំដោះស្រាយវិវាទការងាររួមចំនួន ៣ ចំណុច ដោយបានទទួលលទ្ធផលសះជានឹងគ្នាចំនួន ១ ចំណុច។ ចំណុចមិនសះជាចំនួន ២ ចំណុចនេះត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ២៨៣/១២ ក.ប/កណចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគី

និយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២ ចំណុចនេះ នៅថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកពុំមានវត្តមាននៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ចំណែកភាគីកម្មករនិយោជិតចូលរួមសវនាការតាមការកោះអញ្ជើញ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចធ្វើសវនាការ ដោយកំបាំងមុខភាគីនិយោជក។ ដូចនេះ សេចក្តីបង្គាប់ក្នុងសំណុំរឿងនេះ ជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយចំណុចវិវាទនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សីនិងអ្នកជំនាញក្រៅពីភាគី៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក-ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ-ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យសំណាងកម្មករនៃរោងចក្រកាត់ដេរ ស្តារ នីតធីង ចុះបញ្ជិកា លេខ ១៧៤៩ កប/វក. ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១២ ។

២- សេចក្តីបញ្ជាក់របស់ក្រុមហ៊ុន ស្តារ នីតធីង សូមបញ្ជាក់ថាកម្មករ-កម្មការិនី បានស្ម័គ្រចិត្តចូលជាសមាជិកសហជីពប្រជាធិបតេយ្យសំណាងកម្មករ និងបានអនុញ្ញាតឱ្យក្រុមហ៊ុនកាត់វិភាគទាន ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១។

៣- បញ្ជីរាយនាមកម្មករ-កម្មការិនីនៃក្រុមហ៊ុន ស្តារ នីតធីង ទាំងអស់គ្នាចូលជាសមាជិកសហជីពប្រជាធិបតេយ្យសំណាងកម្មករ និងបានអនុញ្ញាតិឱ្យក្រុមហ៊ុនកាត់វិភាគទានចំនួន ១០០០ រៀល ជូនទៅសហជីពប្រជាធិបតេយ្យសំណាងកម្មករជារៀងរាល់ខែ។

៤- កំណត់ហេតុស្តីពីការអង្កេតស្ថានភាពក្រុមហ៊ុន ស្តារ នីតធីង ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២។

៥- កំណត់ហេតុស្តីអំពីក្រុមហ៊ុន ស្តារ នីតធីង ពិភាក្សាជាមួយកម្មករ ក្នុងគោលបំណងព្យួរការងារបន្ត រយៈពេលពីរខែ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២។

៦- កំណត់ហេតុស្តីពីការចុះអង្កេតការព្យួរកិច្ចសន្យាការងារចំនួន ៣៩៥ នាក់ រយៈពេលពីរខែ នៅក្រុមហ៊ុន ស្តារ នីតធីង ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១។

គ-ឯកសារបានទទួលពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស្តារនីតធីង លេខ ២៨៣/១២ គប/កណ្ត ចុះថ្ងៃទី ២៦ខែ មីនាឆ្នាំ ២០១២ ។

THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ស្តារ នីតធីង ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២។

ឃ-ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៣៧១ កប/អក/វក/លកអ. ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៣៧២ កប/អក/វក/លកអ.ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ស្តារ នីតធីង គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានជួលកម្មករនិយោជិតចំនួនប្រមាណ ៣៨៨ នាក់។
- សហជីពប្រជាធិបតេយ្យសំណាងកម្មករជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកគិតប្រាក់ឈ្នួលស្មើនឹង ៥០% នៃប្រាក់ឈ្នួលសរុប ចំពោះកម្មករនិយោជិត ដែលមិនបានចូលធ្វើការ ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ៥០ ភាគរយ នៃប្រាក់ឈ្នួលសរុប ចំពោះ កម្មករនិយោជិតចំនួន ១៥៨ នាក់ ដែលមិនបានត្រឡប់ចូលធ្វើការវិញ តាំងពីថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១២។ នៅក្នុងចំណុចនេះ ភាគីកម្មករនិយោជិតទាមទារ ពីថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១២ ដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១២។
- មានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៣៩៥ នាក់ ចាប់ពីថ្ងៃទី២៥ តុលា ឆ្នាំ២០១១ ដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។ មូលហេតុ គឺមកពីក្រុមហ៊ុនមិនសូវមានខោអាវឱ្យកម្មករនិយោជិតធ្វើ ព្រោះថាមិនសូវសម្បូរអ្នកបញ្ជាទិញ ដែលធ្វើឱ្យសង្វាក់ផលិតកម្មរបស់រោងចក្រ មានភាពមិនប្រក្រតី និងជួបនូវវិបត្តិខាងហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ។
- មានការព្យួរកិច្ចសន្យាការងារទៀត នៅក្នុងខែមករា និងខែកុម្ភៈ ដោយមូលហេតុគ្មានអ្នកបញ្ជាទិញដដែល។ ភាគីនិយោជកបានសន្យាថា នឹងបើកដំណើរការផលិតកម្មឡើងវិញ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ

២០១២ ហើយកម្មករនិយោជិតត្រូវត្រឡប់ចូលធ្វើការវិញ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។

- នៅក្នុងខែមីនា ឆ្នាំ២០១១ មានកម្មករនិយោជិតចំនួន ២៣០ នាក់ ត្រលប់ចូលទៅក្រុមហ៊ុន ដើម្បីធ្វើការ។ ដោយឡែកកម្មករនិយោជិតចំនួន ១៥៨ នាក់ មិនបានទៅក្រុមហ៊ុនតែម្តង កាលពីខែមីនា ឆ្នាំ២០១២ នោះ។ ក្រុមហ៊ុននៅតែមិនទាន់មានការងារធ្វើ ចាប់ពីខែមីនា នេះមក ប៉ុន្តែ ភាគីនិយោជកបានផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ដល់កម្មករនិយោជិតទាំង ២៣០ នាក់ ដែលបានមកបង្ហាញខ្លួននៅក្រុមហ៊ុន សម្រាប់ ១០ថ្ងៃដំបូង នៃខែមីនា ឆ្នាំ២០១២ និងផ្តល់ប្រាក់ឈ្នួល ៥០ ភាគរយ ដល់ពួកគាត់សម្រាប់រយៈពេលនៅសល់នៃខែមីនានោះ។
- ភាគីនិយោជកមិនបានផ្តល់ប្រាក់ឈ្នួលអ្វីទាំងអស់ដល់កម្មករនិយោជិតចំនួន ១៥៨ នាក់ ផ្សេងទៀត ដែលមិនបានទៅបង្ហាញខ្លួននៅក្រុមហ៊ុនទាល់តែសោះ។ ភាគីនិយោជកបានចាត់ទុកថា កម្មករនិយោជិតទាំង ១៥៨ នាក់ បានបោះបង់ចោលការងារ។

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកលុយអាណត្តិកិច្ចសន្យាការងារ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារចំនួន ៥ ភាគរយនៃប្រាក់ឈ្នួល ដែលបើកបានក្នុងអំឡុងពេលនៃកិច្ចសន្យា ដែលពួកគាត់ត្រូវទទួលបានតាំងពីថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១២។
- ចំពោះកម្មករនិយោជិត ដែលមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ជាទូទៅនៅពេលដល់កាលកំណត់កិច្ចសន្យានីមួយៗ ភាគីនិយោជកតែងផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារចំនួន ៥ ភាគរយ នេះ ទោះបីជាមានការបន្តកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលានោះឡើងវិញក៏ដោយ។
- ចាប់ពីពេលក្រុមហ៊ុនគ្មានការងារធ្វើមក កម្មករនិយោជិតស្ទើរតែទាំងអស់ ដែលមានកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាដល់កាលកំណត់ និងត្រូវបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារចំនួន ៥ ភាគរយ នេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ មិនទាន់ទទួលបានប្រាក់បំណាច់របស់ពួកគាត់ទេ។
- ទោះបីជាក្រុមហ៊ុនគ្មានការងារធ្វើ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនទាន់សម្រេចលាលែងពីការងារ ហើយភាគីនិយោជកមិនទាន់បានសម្រេចបិទក្រុមហ៊ុន ឬផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ដែលទាមទារក្នុងសំណុំរឿងនេះទេ។

## ហេតុផលនៃសេចក្តីសម្រេច ÷

នៅថ្ងៃសវនាការភាគីនិយោជកមិនមានវត្តមាន តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ មុននឹងធ្វើការបកស្រាយលើចំណុចវិវាទនៅក្នុងសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលធ្វើការពិចារណាថា តើអាជ្ញាកណ្តាលអាចធ្វើសវនាការដោយកំបាំងមុខភាគីនិយោជកដែរ ឬទេ?

THE ARBITRATION COUNCIL

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា “*ក្នុងករណីភាគីណាមួយ បានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ ។*”

ទាក់ទងនឹងខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ នេះ នៅក្នុងសំណុំរឿងមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគី ដែលអវត្តមាននោះ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤-គួងហុង, លេខ ៦៣/០៤-សាញូវែល, លេខ ១៤៨/០៧-ចាយហឹ, លេខ ៩៩/០៩-យីងឡៃទ និងលេខ ១៧៣/១១-ជិនអ៊ីង*) ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក និងភាគីកម្មករនិយោជិតបានទទួលការអញ្ជើញត្រឹមត្រូវ ឱ្យចូលរួមសវនាការពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែនៅថ្ងៃសវនាការមានតែភាគីកម្មករនិយោជិតទេ ដែលបានចូលរួមសវនាការតាមការអញ្ជើញ។ ចំណែកឯភាគីនិយោជកមិនបានចូលរួមសវនាការតាមការអញ្ជើញទេ ហើយភាគីនិយោជកពុំមានបញ្ជាក់មូលហេតុត្រឹមត្រូវក្នុងការមិនចូលរួមសវនាការនោះដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសំរេចបន្តដំណើរការរបស់ខ្លួន ដោយបើកសវនាការកំបាំងមុខភាគីនិយោជក ។

**ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលស្មើនឹង ៥០% នៃប្រាក់ឈ្នួលសរុប ចំពោះកម្មករនិយោជិត ដែលមិនបានចូលធ្វើការ ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១២**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលស្មើនឹង ៥០ ភាគរយនៃប្រាក់ឈ្នួលសរុប ចំពោះកម្មករនិយោជិតដែលមិនបានចូលធ្វើការពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២ ដែរ ឬទេ?

មាត្រា ៦៥ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា “*កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើត ឱ្យមានការទាក់ទងផ្នែកការងារ កម្មករនិយោជិត និងនិយោជក ។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា ។*”

មាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណី ដែលត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ត្រង់ជំពូកទី៩ ស្តីពីកិច្ចសន្យាការងារ កថាខណ្ឌទី១ ចែងថា “*១. កិច្ចសន្យាការងារ ត្រូវបានបង្កើតឡើង ដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួលទៅលើកិច្ចការពលកម្មនោះ ។*”

THE ARBITRATION COUNCIL

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ភាគីនិយោជកបានប្រកាសថា ការព្យួរកិច្ចសន្យាចុងក្រោយ គឺ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ និងបានប្រកាសថា ក្រុមហ៊ុននឹងដំណើរការឡើងវិញ នៅក្នុងខែមីនា ឆ្នាំ២០១២ ហើយកម្មករនិយោជិតត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ មានកម្មករនិយោជិតសរុបចំនួន ២៣០ នាក់ បានត្រលប់ចូលទៅក្រុមហ៊ុន ដើម្បីធ្វើការ។ ក៏ប៉ុន្តែកម្មករនិយោជិតចំនួន ១៥៨ នាក់ ដែលទាមទារក្នុងសំណុំរឿងនេះ មិនបានចូលមកធ្វើការវិញ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ តែម្តងទេ ខណៈពេលដែលកម្មករនិយោជិត ២៣០ នាក់ ផ្សេង បានចូលធ្វើការវិញ តាមការប្រកាសឱ្យចូលធ្វើការវិញរបស់ភាគីនិយោជក។ ពោលគឺកម្មករនិយោជិតទាំង ១៥៨ នាក់ មិនបានត្រលប់ចូលទៅធ្វើការនៅក្នុងក្រុមហ៊ុនវិញទេ ក្រោយពេលការព្យួរកិច្ចសន្យាការងារនាពេលនោះត្រូវបានបញ្ចប់។

យោងតាមកថាខណ្ឌទី១ នៃ មាត្រា៦៦៤ នៃក្រមរដ្ឋប្បវេណីខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានកិច្ចសន្យា និងទំនាក់ទំនងការងារកើតឡើងរវាងភាគីកម្មករនិយោជិតទាំង ១៥៨ នាក់ នេះ និងភាគីនិយោជក ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១២ នោះទេ ពីព្រោះកម្មករនិយោជិតទាំង ១៥៨ នាក់ មិនបានបំពេញកាតព្វកិច្ចតាមការសន្យាថា នឹងធ្វើការជូននិយោជក តាមរយៈការមិនបានត្រលប់ចូលទៅក្រុមហ៊ុន ក្នុងគោលបំណងដើម្បីបំពេញការងាររបស់ខ្លួន ក្រោយពីការព្យួរការងារត្រូវបានបញ្ចប់។ ហេតុនេះ ភាគីនិយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតទាំង ១៥៨ នាក់នេះឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលស្មើនឹង ៥០ ភាគរយ នៃប្រាក់ឈ្នួលសរុប ចំពោះកម្មករនិយោជិតទាំង ១៥៨ នាក់ ដែលមិនបានចូលធ្វើការ ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២។

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលានៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២**

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាចំនួន ៥ ភាគរយ ជូនកម្មករនិយោជិត នៅពេលដែលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានីមួយៗរបស់ពួកគាត់ដល់កាលបរិច្ឆេទផុតកំណត់ និងដែលត្រូវបើកកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។ ទោះបីជាក្រុមហ៊ុនគ្មានការងារធ្វើ ប៉ុន្តែភាគីកម្មករនិយោជិតមិនទាន់សម្រេចលាលែងពីការងារ ហើយភាគីនិយោជកក៏មិនទាន់បានសម្រេចបិទក្រុមហ៊ុន ឬផ្តាច់កិច្ចសន្យាការងារកម្មករនិយោជិត ដែលទាមទារក្នុងសំណុំរឿងនេះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន៥ភាគរយជូនកម្មករនិយោជិត នៅពេលមិនទាន់កាត់ផ្តាច់ទំនាក់ទំនងការងារដែរ ឬទេ?

មាត្រា ៧៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ត្រង់កថាខណ្ឌទី១ បានចែងថា "*កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់តាមធម្មតានៅពេលដល់កាលកំណត់។ ប៉ុន្តែកិច្ចសន្យានេះ អាចរំលាយមុនកាលកំណត់តាមការព្រមព្រៀងរបស់ភាគីទាំងសងខាងក្នុងល័ក្ខខ័ណ្ឌ ដែលការព្រមព្រៀងនេះធ្វើឡើងជាលាយល័ក្ខណ៍អក្សរនៅចំពោះមុខអធិការការងារ និងចុះហត្ថលេខាដោយភាគីទាំងពីរនៃកិច្ចសន្យា* "។

THE ARBITRATION COUNCIL

មាត្រា ៧៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ត្រង់កថាខណ្ឌទី៦ បានចែងថា “*នៅពេលបញ្ចប់កិច្ចសន្យា និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យានោះ ដែលសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងថិរវេលានៃកិច្ចសន្យាផង ហើយដែលចំនួនប្រាក់បំណាច់នេះមានកំណត់ក្នុងអនុសញ្ញារួម ។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះយ៉ាងតិចត្រូវស្មើប្រាំភាគរយនៃប្រាក់ឈ្នួល ដែលកម្មករនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា ។*”

ក្រុមអាជ្ញាកណ្តាលយល់ឃើញថា ខ្លឹមសារនៅក្នុងមាត្រានេះអាចត្រូវបានបកស្រាយជាច្រើនបែប ។

វាមិនមានលក្ខណៈច្បាស់លាស់ចំពោះឃ្លា ដែលនិយាយថា “*នៅពេលបញ្ចប់កិច្ចសន្យា*” ពីព្រោះគេមិនដឹងថា តើឃ្លានេះចង់សំដៅលើការបញ្ចប់កិច្ចសន្យារបស់កម្មករនិយោជិតម្តងៗ ហើយបន្តជាថ្មី ឬជាការផ្តាច់ទំនាក់ទំនងការងារ ។ ពោលគឺការបញ្ចប់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាចុងក្រោយរបស់កម្មករនិយោជិត ដោយគ្មានការបន្តសារជាថ្មី ។

ទោះបីជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រានេះ ចង់សំដៅលើ “*ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា*” ។ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាគួរត្រូវបានគេបកស្រាយថា ជាប្រាក់បំណាច់ដែលត្រូវបង់នៅពេលទំនាក់ទំនងការងារត្រូវបានកាត់ផ្តាច់ ឬនៅពេលបញ្ចប់នៃទំនាក់ទំនងការងារ ពោលគឺបញ្ចប់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាចុងក្រោយ ដោយមិនមានការបន្តទំនាក់ទំនងការងារសារជាថ្មីរវាងនិយោជក និងកម្មករនិយោជិត ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧៦/០៦-សៅធ៍ បេ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា “*និយោជកមិនជាប់កាតព្វកិច្ចត្រូវបង់ប្រាក់បំណាច់ចំនួន ៥ ភាគរយនៃកិច្ចសន្យាការងារមានថិរវេលាកំណត់ នៅពេលកិច្ចសន្យាការងារមានថិរវេលាកំណត់នីមួយៗបញ្ចប់ទេ បើទំនាក់ទំនងការងារនៅតែបន្ត ។ កម្មករអាចទទួលបានប្រាក់បំណាច់កិច្ចសន្យាការងារ ៥ ភាគរយនេះ នៅពេលដែលកិច្ចសន្យាការងារមានថិរវេលាកំណត់ត្រូវបានបញ្ចប់ ហើយទំនាក់ទំនងការងារត្រូវបានកាត់ផ្តាច់ ។ ប្រសិនបើកិច្ចសន្យាការងារមួយត្រូវបានបន្តសារជាថ្មីនៅចុងបញ្ចប់របស់វា គេមិនអាចចាត់ទុកថា ទំនាក់ទំនងការងារត្រូវបានកាត់ផ្តាច់ឡើយ ពីព្រោះទំនាក់ទំនងការងារនៅតែបន្តដដែល ហើយអត្ថប្រយោជន៍ផ្សេងៗក៏នឹងត្រូវបន្តទៅតាមកិច្ចសន្យាការងារថ្មីផងដែរ*” ។ (សូមមើលសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ*៦០/០៦-ញូមេក ហ្គាមេន ហេតុផលចំណុចវិវាទទី៦ និងលេខ ៧៦/០៦-សៅធ៍ បេ ហេតុផលចំណុចវិវាទទី១*) ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺកម្មករនិយោជិតទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលា នៅពេលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវបានបញ្ចប់ ហើយដែលទំនាក់ទំនងការងារក៏ត្រូវបានបញ្ចប់ដែរ ។ ប្រសិនបើកិច្ចសន្យាការងារមួយត្រូវបានបន្តសារជាថ្មីនៅចុងបញ្ចប់របស់វា គេមិនអាចចាត់ទុកថា ទំនាក់ទំនងការងារត្រូវបានកាត់ផ្តាច់ឡើយ ពីព្រោះទំនាក់ទំនងការងារនៅតែបន្តដដែល ហើយអត្ថប្រយោជន៍ផ្សេងៗក៏នឹងត្រូវបន្តទៅតាមកិច្ចសន្យាការងារថ្មីផងដែរ ។

យោងតាមអង្គហេតុ កម្មករនិយោជិតដែលទាមទារនៅក្នុងសំណុំរឿងនេះ មិនទាន់ឈប់ពីការងារ

ARBITRATION COUNCIL

ហើយនិយោជកមិនទាន់បានបិទក្រុមហ៊ុន និង/ឬ មិនទាន់បានកាត់ផ្តាច់កិច្ចសន្យាការងាររបស់ពួកគាត់ឡើយ ទោះបីជានិយោជកមិនទាន់មានការងារគ្រប់គ្រាន់ឱ្យកម្មករនិយោជិតធ្វើក៏ដោយ។ ហេតុនេះ ទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជកនៅតែមាន និងមិនទាន់កាត់ផ្តាច់ទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យនិយោជកបង់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៥ ភាគរយ នៅពេលដែលមិនទាន់មានការកាត់ផ្តាច់ទំនាក់ទំនងការងាររវាងភាគីទាំងពីរ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលស្មើនឹង ៥០ ភាគរយ នៃប្រាក់ឈ្នួលសរុប ចំពោះកម្មករនិយោជិតទាំង ១៥៨ នាក់ ដែលមិនបានចូលធ្វើការពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២។

**ចំណុចវិវាទទី ២ ៖**

បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យនិយោជកបង់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលា ៥ ភាគរយ នៅពេលមិនទាន់មានការកាត់ផ្តាច់ទំនាក់ទំនងការងារ រវាងនិយោជក និងកម្មករនិយោជិត។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរបន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជកៈ

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា ៖ ---------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិតៈ

ឈ្មោះ ៖ **អេន ណាន**

ហត្ថលេខា ៖ ---------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាលៈ

ឈ្មោះ ៖ **រួន សារ៉ាយ**

ហត្ថលេខា ៖ ---------------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL